# ពិធីសម្ពោធន៍ពាក្យស្លោករំឭកពីការប្រឆាំងអំពើប្រល័យពូជសាសន៍

## វិទ្យាល័យព្រះស៊ីសុវត្ថិ

### ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១០

មជ្ឈមណ្ឌលឯកសារកម្ពុជា នឹងមានការរៀបចំដាក់ពាក្យស្លោករំឭកពីការប្រឆាំងអំពើប្រល័យពូជសាសន៍ នៅវិទ្យាល័យព្រះស៊ីសុវត្ថិ ដែលនឹងប្រារព្ធធ្វើពិធីសម្ពោធន៍នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១០ នៅវេលាម៉ោង៧និង៣០នាទីព្រឹក និងមានការចូលរួមជាកិត្តិយសពីសំណាក់ លោកជំទាវ ទន់ សាអ៊ឹម អនុរដ្ឋលេខាធិការ នៃក្រសួងអប់រំ យុវជន និងកីឡា និងលោក ជា ជាតិ ប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ ។ វិទ្យាល័យព្រះស៊ីសុវត្ថិ គឺជាវិទ្យាល័យទីបី ចំពោះការដាក់ពាក្យស្លោកនេះ បន្ទាប់ពីវិទ្យាល័យ ឥន្ទ្រទេវី និងបុស្សឫកែវ ។ គម្រោងបន្ទាប់របស់យើង គឺនឹងប្រារព្ធធ្វើនៅវិទ្យាល័យ ហ៊ុន សែន អង្គស្នួល នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១០ ។ លើសពីនេះទៅទៀត មជ្ឈមណ្ឌលឯកសារកម្ពុជា នឹងរៀបចំដាក់ពាក្យស្លោកនេះនៅវិទ្យាល័យផ្សេងៗទៀតទាំងអស់ ឲ្យបានរួចរាល់នៅក្នុងឆ្នាំ២០១១ ។

វិទ្យាល័យព្រះស៊ីសុវត្ថិ បានក្លាយជាវិទ្យាល័យដំបូងបង្អស់ នៅក្នុងឆ្នាំ១៩៣៥ ដែលមានឈ្មោះថា វិទ្យាល័យព្រះស៊ីសុវត្ថិ “Collège Sisowath” គឺជាវិទ្យាស្ថានអប់រំកម្រិតវិទ្យាល័យតែមួយគត់នៅទីក្រុងភ្នំពេញ ។ នៅក្នុងឆ្នាំ១៩៧៥ ពេលដែលខ្មែរក្រហមបានចូលកាន់កាប់ទីក្រុងភ្នំពេញ សាលារៀនទាំងអស់ត្រូវបានបិទទ្វារទាំងស្រុង និងបានប្រើប្រាស់ជាមជ្ឈមណ្ឌលសម្រាប់បណ្តុះបណ្តាលផ្នែកនយោបាយ និងវេជ្ជសាស្ត្រ ហើយក៏ជាកន្លែងនៃការចាប់ផ្តើមចលនាកុម្មុយនិស្តដំបូងបង្អស់ដែរ ។ នៅក្នុងចំណោមប្រជាជនកម្ពុជា ក៏មានសិស្សានុសិស្សនិងគ្រូបង្រៀនដែលត្រូវបានជម្លៀសចេញពីក្រុងធ្វើទុក្ខបុកម្នេញ និងសម្លាប់ក្រោមការគ្រប់គ្រងរបស់អ្នកដឹកនាំកុម្មុយនិស្ត មានដូចជា ប៉ុល ពត, អៀង សារី, ខៀវ សំផន, អៀង ធីរិទ្ធ និង នួន ជា ។ អ្នកទាំងនោះ ក៏ធ្លាប់ជាអតីតសិស្សនៅវិទ្យាល័យនេះដែរ ។ ដោយថាហេតុ វិទ្យាល័យនេះត្រូវបានបើកទ្វារឡើងវិញ បន្ទាប់ពីរបបខ្មែរក្រហមត្រូវបានដួលរលំនៅក្នុងឆ្នាំ១៩៧៩ ដោយមានឈ្មោះថា វិទ្យាល័យភ្នំដូនពេញ ។ ក្រោយមកទៀតត្រូវបានប្តូរឈ្មោះមកជា វិទ្យាល័យព្រះស៊ីសុវត្ថិ ដែលត្រូវបានប្រើប្រាស់រហូតមកដល់សព្វថ្ងៃនេះ ។

នៅក្នុងកម្មវិធីបើកសម្ពោធន៍ពាក្យស្លោក មជ្ឈមណ្ឌលឯកសារកម្ពុជាក៏នឹងមានការចែកជូននូវទស្សនាវដ្តី “ស្វែងរកការពិត” និងផ្ទាំងរូបភាព ដែលអប់រំអំពីការទប់ស្កាត់នៃអំពើប្រល័យពូជសាសន៍

ដល់សិស្សានុសិស្ស និងសៀវភៅសំណុំរឿង០០២ ទៅដល់លោកគ្រូអ្នកគ្រូ ដើម្បីស្វែងយល់បន្ថែមអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ដំណើរការរបស់សាលាក្តីខ្មែរក្រហម និងរឿងរ៉ាវផ្ទាល់ខ្លួនរបស់ជនរងគ្រោះជាច្រើនទៀត។ លោកជំទាវ ទន់ សាអ៊ីម នឹងផ្តល់កិច្ចសំណេះសំណាលអំពីសារប្រយោជន៍ ក្នុងការសិក្សាអំពីរបបកម្ពុជាប្រជាធិបតេយ្យ និងផ្តល់អនុសាសន៍ដល់លោកគ្រូអ្នកគ្រូ ក្នុងការបង្រៀនអំពីប្រវត្តិសាស្ត្ររបបនេះ ដល់សិស្សានុសិស្សប្រកបដោយប្រសិទ្ធិភាព។ ពាក្យស្លោកនេះ អប់រំដល់សិស្សានុសិស្សឲ្យយល់នូវសារសំខាន់នៃការផ្សះផ្សា អត់ឱនអធ្យាស្រ័យគ្នាទៅវិញទៅមក និងប្រឈមមុខនឹងប្រវត្តិសាស្ត្រឈឺចាប់របស់ខ្លួនដោយសន្តិវិធី។

ការរៀបចំពាក្យស្លោកនេះ គឺមានការឧបត្ថម្ភផ្នែកថវិកា ពីបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ព្រមទាំងមិត្តភក្តិជាច្រើនទៀត ដែលធ្លាប់ជាអតីតសិស្សនៅវិទ្យាល័យព្រះស៊ីសុវត្ថិ។ ក្រៅពីមូលហេតុនៃការអប់រំពីអំពើប្រល័យពូជសាសន៍ដ៏សំខាន់នេះ នេះក៏ជាឱកាសដ៏ប្រសើរមួយសម្រាប់ការជួបជុំឡើងវិញ រវាងអតីតសិស្សវិទ្យាល័យព្រះស៊ីសុវត្ថិជាច្រើនជំនាន់ ដើម្បីពិភាក្សាបន្ថែមអំពីភាពចាំបាច់ ក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងជំរុញឲ្យមានការសហការ ដើម្បីធ្វើឲ្យការដាក់ពាក្យស្លោកនេះសម្រេចទៅបាន។ មជ្ឈមណ្ឌលឯកសារកម្ពុជា នឹងបន្តលើកទឹកចិត្តដល់បុគ្គលិកទាំងអស់ ឲ្យរៀបចំដាក់ពាក្យស្លោកនេះនៅតាមអតីតវិទ្យាល័យរបស់ខ្លួន ក៏ដូចជាវិទ្យាល័យផ្សេងៗទៀត ទាំងនៅក្រុងភ្នំពេញ និងនៅតាមបណ្តាខេត្តជាច្រើនទៀត។